DECENT WORK

A better world starts here.

International Labour Organization

សេចក្តីប្រកាសព័ត៌មាន Press Release

# ស្តង់ដាថ្មីរបស់អង្គការអន្តរជាតិខាងការងារនឹងជួយដល់អ្នកធ្វើការងារបម្រើតាមផ្ទះចំនួន ២១.៥ លាននាក់

សម្រាប់ការចេញផ្សាយ: ថ្ងៃពុធ ទី០៨ ខែមេសា ឆ្នាំ២០១៥

ព័ត៌មានអង្គការអន្តរជាតិខាងការងារ (ភ្នំពេញ) យោងតាមការបោះពុម្ពផ្សាយថ្មីមួយស្តីពី "ស្តង់ដាសមត្ថភាពគំរូប្រចាំតំបន់សម្រាប់ការងារបម្រើតាមផ្ទះ" ដោយអង្គការអន្តរជាតិខាងការងារ (ILO) មានអ្នកធ្វើការងារបម្រើតាមផ្ទះដែលមានចំនួនច្រើនជាង ២០លាននាក់ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកនឹងទទួលបានអត្ថប្រយោជន៍ពីស្តង់ដាសមត្ថភាពគំរូប្រចាំតំបន់ (Regional Model Competency Standards – RMCs)។ ប៉ុន្តែការណ៍នេះនឹងកើតមានទៅបាន លុះត្រាតែស្តង់ដាសមត្ថភាពគំរូប្រចាំតំបន់ (RMCs) ត្រូវបានយកទៅប្រើសម្រាប់ការធ្វើសមារណកម្ម តំបន់អាស៊ាន ដោយធានាឲ្យមានការទទួលស្គាល់ជំនាញទៅវិញទៅមករបស់កម្មករនិយោជិតឆ្លងដែនទាំងអស់។

"ការប្រើប្រាស់ស្តង់ដាសមត្ថភាពគំរូប្រចាំតំបន់ (RMCs) នឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់អ្នកធ្វើការងារបម្រើតាមផ្ទះនៅក្នុងតំបន់" តាមការលើកឡើងរបស់លោកស្រី Tomoko Nishimoto ជាជំនួយការអគ្គនាយក និងជានាយកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិករបស់អង្គការអន្តរជាតិខាងការងារ។ "ស្តង់ដាសមត្ថភាពគំរូប្រចាំតំបន់ (RMCs) ជាស្តង់ដាយោងនៅកម្រិតតំបន់ ដែលអាចប្រើសម្រាប់ការអភិវឌ្ឍជំនាញប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ជាអាទិ៍ តាមរយៈការរៀបចំ និងអនុវត្តការបណ្តុះបណ្តាល តាមរយៈការវាយតម្លៃពីលទ្ធផលនៃការបណ្តុះបណ្តាល និងសម្តភាពជំនាញដែលមានស្រាប់របស់បុគ្គល"។ តាមការប៉ាន់ប្រមាណរបស់អង្គការ ILO ក្នុងឆ្នាំ ២០១០ មានអ្នកធ្វើការងារបម្រើតាមផ្ទះប្រមាណ ២១.៥ លាននាក់ ឬ ៤០.៨ ភាគរយនៃអ្នកធ្វើការសរុបនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

ស្តង់ដាសមត្ថភាពគំរូប្រចាំតំបន់ (RMCs) គ្របដណ្តប់កិច្ចការសំខាន់របស់អ្នកធ្វើការងារបម្រើតាមផ្ទះ រួមមានការសម្អាត គេហកិច្ច ការចម្អិនម្ហូបអាហារ និងការរៀបចំម្ហូបអាហារ ការមើលថែទារកនិងកុមារ ការមើលថែមនុស្សចាស់ ការចិញ្ចឹមសត្វ និងថែសួនប្រចាំគ្រួសារ។ ស្តងដាសម្តភាពនេះមានរួមបញ្ចូលទាំងសមត្ថភាពស្នូលនៃជំនាញខាងការប្រាស្រ័យទាក់ទង ការរៀបចំ និងការចាត់ចែងការងារផ្ទាល់របស់ខ្លួន។ ស្តង់ដាសមត្ថភាពគំរូប្រចាំតំបន់ (RMCs) ក៏នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រទេសនានាដែលកំពុងអភិវឌ្ឍស្តង់ដាជាតិ ឬកំពុងពិនិត្យមើលឡើងវិញអំពីស្តង់ដាដែលមានស្រាប់។

"ពលករឆ្លងដែនជាច្រើនមានជំនាញដែលទទួលបាននៅក្នុងប្រទេសកំណើតរបស់ខ្លួន ប៉ុន្តែជំនាញទាំងអស់នោះមិនត្រូវបានបញ្ជាក់ជាផ្លូវការនោះទេ" តាមប្រសាសន៍របស់លោកស្រី Akiko Sakamoto អ្នកឯកទេសខាងជំនាញ និងភាពមានការងារធ្វើនៃអង្គការ ILO។ "ស្តង់ដាសមត្ថភាពគំរូប្រចាំតំបន់ (RMCs) ទាំងនេះ ជាការចំបាច់សម្រាប់ការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងដើម្បីធានាឲ្យមានការធ្វើសមាហរណកម្មកាន់តែប្រសើររបស់ពួកគេ នៅក្នុងប្រទេសកំណើតរបស់ខ្លួន" ។



ILO Regional Office for Asia and the Pacific
United Nations Building, 11th Floor,
Rajdamnern Nok Avenue, Bangkok 10200, Thailand

Tel. +66 2 288 1234
Fax. +66 2 288 3062
Email: bangkok@ilo.org
www.ilo.org/asia

For information only. Not an official record.

DECENT WORK
A better world starts here.

International Labour Organization

ការបោះពុម្ពផ្សាយនេះគូសបញ្ជាក់ថាកម្មវិធី និងគោលនយោបាយរបស់រដ្ឋាភិបាល ត្រូវតែលើកទឹកចិត្តឲ្យមានការអភិវឌ្ឍបន្តនូវសមត្ថភាព និងគុណវុឌ្ឍិរបស់អ្នកធ្វើការងារបម្រើតាមផ្ទះ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការកសាងវិជ្ជាជីវៈ និងឱកាសការងាររបស់ពួកគេ។ "ត្រូវតែមានការជំរុញឲ្យមានការលើកកម្ពស់ការងារសមរម្យសម្រាប់អ្នកធ្វើការងារបម្រើតាមផ្ទះ។ ការអភិវឌ្ឍ និងការទទួលស្គាល់ជំនាញរបស់អ្នកធ្វើការងារបម្រើតាមផ្ទះ រួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមនេះ ពិសេសក្នុងន័យសមាហរណកម្មអាស៊ានក្នុងឆ្នាំ២០១៥" តាមប្រសាសន៍លោកស្រី Carmela Torres អ្នកឯកទេសជាន់ខ្ពស់ខាងជំនាញ និងភាពមានការងារធ្វើនៃអង្គការ ILO។ លោកស្រីបានមានប្រសាសន៍បន្តថា "កិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធគឺជាគន្លឹះទៅរកជោគជ័យ។ អង្គការILO ដែលជាតួអង្គដ៏សំខាន់មួយខាងបញ្ហាការងារ ប្តេជ្ញាចិត្តដល់ជំនួយបច្ចេកទេស និងសេវាប្រឹក្សាយោបល់តាមបែបផែនជាច្រើន ក្នុងផ្នែកទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក"។

ការបោះពុម្ពផ្សាយនេះត្រូវបានបង្កើតឡើងដោយអ្នកជំនាញការ ដែលធ្វើការងារសម្រាប់កម្មវិធីជំនាញប្រចាំតំបន់របស់អង្គការ ILO ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក។ កម្មវិធីនេះក៏រៀបចំដំណើរការសហគមន៍ប្រតិបត្តិសម្រាប់ជំនាញ និងភាពមានការងារធ្វើ ប្រចាំអាស៊ីប៉ាស៊ីហ្វិក (Asia Pacific Skills and Employability Community of Practice (CoP) ដែលជាវេទិកាពិគ្រោះយោបល់តាមប្រព័ន្ធគេហទំព័រ សម្រាប់ការផ្លាស់ប្តូរ និងការចែករំលែកចំណេះដឹង និងបទពិសោធន៍ផ្នែកប្រធានបទពាក់ព័ន្ធជំនាញ និងភាពមានការងារធ្វើ។

Press Release សេចក្តីប្រកាសព័ត៌មាន

សម្រាប់ព័ត៌មានបន្ថែមសូមមេត្តាទាក់ទង:

លោកស្រី Carmela Torres
អ្នកឯកទេសជាន់ខ្ពស់ខាងជំនាញ និងភាពមានការងារធ្វើនៃអង្គការ ILO
ទូរស័ព្ទ +662 2881780
E-mail: torres@ilo.org

លោកស្រី Onpreeya Chitpakdee
មន្ត្រីទទួលបន្ទុកកម្មវិធីជំនាញប្រចាំតំបន់នៃអង្គការ ILO
ទូរស័ព្ទ +662 288 2244
E-mail: onpreeya@iloguest.org

លោក ទុន សុភ័ណ
អ្នកសម្របសម្រួលជាតិនៃអង្គការ ILO ប្រចាំកម្ពុជា
ទូរស័ព្ទ +855 23 220 817
E-mail: tun@ilo.org



For information only. Not an official record.